# គតិបណ្ឌិត: *សំណាបយោងដី...*

## «សំណាបយោងដី ស្រីយោងប្រុស ពូថៅយោងខ្វស ច្រមុះយោងថ្ពាល់»

..........

*សិល្បៈសំដី*

*បុរាណកវី ប្រៀបធៀបឧបមា*
*កំប៉ុកកំប្លែង ថ្លែងរាយរៀបរាប់*
*បង្កប់ខ្លឹមសារ មានជ្រៅមានរាក់ ។*

**សំណាបយោងដី**

*គតិប្រពៃ ក្នុងន័យបញ្ជាក់*
*សំណាបណាល្អ បវរពេញលក្ខណ៍*
*ទោះអស់លោកអ្នក យកស្ទូងស្រែណា ។*

*ស្រែគ្រោកស្រែគ្រាច*

*ស្រែវាលប៉ាចហាច គង់បានផលា*
*ស្ទូងហើយលូតលាស់ បង្ហាញកាយា*
*គេតែងពោលថា ស្រែនោះដីល្អ ។*

**ឯស្រីយោងប្រុស**

*លោកថាមិនខុស មានក្លាយជាក្រ*
*ដូចនាយសំពៅ យកពេជ្រដូរថ្ម*
*ក្បត់ចិត្តស្មោះសរ ពីស្ងួនភរិយា ។*

*ឃើញនាងនារី*

*ស្រីអលង្ការ មានរូបសោភា*
*ប្រពន្ធមាណព តាមដង់ជលធា*
*កំពុងនាំគ្នា ជញ្ជាត់ចាប់ត្រី ។*

*រឿងតូចតាចសោះ*

*បង្កើតជម្លោះ ដូរប្រពន្ធប្តី*

គូដែលសប្បាយ គូលោកសេដ្ឋី
ឯគូភក្តី គឺចៅមាណព ។

ដោយសារតែស្រី

នាងគ្រប់លក្ខណ៍វៃ ឆ្លាតដឹងសព្វគ្រប់
ផ្តល់ជាយោបល់ មិនចេះឈរឈប់
ទើបចៅមាណព ស្គាល់អង្គក្សត្រា ។

មិនតែប៉ុណ្ណោះ

មង្គលរីកដុះ ពេញទាំងគ្រួសារ
កិត្តិយសរន្ទឺ សាយគ្រប់ទិសា
ឯនាយភេត្រា ធ្លាក់ខ្លួនសុំទាន ។

**ពូថៅយោងខុស**

លោកអ្នកចាំចុះ ជូនតាទូន្មាន
ឧសខ្ចូតសាចត្រង់ ឧសថ្នាំងលឹបលៀន
សម្ងំឈរឈាន ចង់ពុះបំបែក ។

អោយប្រើពូថៅ

មានដងត្រឹមត្រូវ ចាត់ទុកជាឯក
ផ្ទៃស៊ីនឹងដង មិនបោរកោងកែក
ទុកដាក់តាមផ្នែក លំដាប់តូចធំ ។

ពេលយកទៅពុះ

មើលប្រភេទឧស ពុះឲ្យចំមុំ
បើឧសសាច់ត្រង់ ប្រើពូថៅធំ
មុខវាក្រពុំ ងាយបំបែកបាន ។

ឧសសាច់កណ្តាញ់

ប្រើអាល្មមវិញ ទើបវាចំណាន
មុខវាមុតល្អ កាប់ចាំងដេះបាន
ទោះថ្នាំងប៉ុន្មាន ពុះបានទាំងអស់ ។

## ច្រមុះយោងផ្កាល់

អ្នកគិតឲ្យដល់ កុំធ្វើឡេះឡោះ
មិច្ឆាទិដ្ឋិ នាំឲ្យវង់គ្រោះ
ឃើញថ្កាល់គេស្រស់ ចង់ស្រោចស្រឹង្ការ ។

នទៀលផ្ដេកផ្ដិត

តាមវិស័យចិត្ត ស្រូបគន្ធមាលា
លើថ្កាល់ផ្ទូរផង់ នៃនាងពិម្ពា
ប្រតិព័ទ្ធវន្ទា នាំតែចំបែង ។

តាមពិតនាសា

យោងថ្កាល់អ្នកណា គឺយោងខ្លួនឯង
ថ្កាល់អន់តិចតួច ឲ្យតែវាខែង
ស្រួចស្រស់ចាំងចែង ដូចស្នែងកក្រ្កា ។

បើផែនថ្កាល់ក្មោះ

មាននាសាខ្ពស់ ហើយទ្រង់វែនតា
នោះរឹតតែធ្វើ អោយវង់កក្រ្កា
លេចឡើងសង្ហា ដូចហង្សបក្សី ។

តែផ្ទុយមកវិញ

ទោះថ្កាល់ប៉ោងពេញ រលោងម៉ដ្ឋខៃ
ចំណែកច្រមុះ ជំស្មៀតខើចខ្ចី
ក្រពិតអប្រិយ យោងថ្កាល់អីកើត ៕

**ឆង ឈាង**

ដកស្រង់ចេញពី ទស្សនាវដ្ដី កម្ពុជសុរិយា
ឆ្នាំទី ៥២ លេខ ៣, ព.ស. ២៥២២

.................

**តិក្ខុវណ្ណគុត្តោ ស្វាត សាលឿម**